**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**រដ្ឋបាលជលផល**

លេខ:..២៣៦៥......ជផ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជួលដាយត្រីលេញ និងដាយបង្គង តាមការព្រមព្រៀង សម្រាប់ធ្វើអាជីវកម្ម ក្នុងរដូវនេសាទឆ្នាំ២០១៩-២០២០និងឆ្នាំ២០២០-២០២១

**យោង** ៖ លិខិតលេខ៣៣៩ ខរជ.៧ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ របស់ខណ្ឌរដ្ឋបាលជលផលព្រៃវែង។

រដ្ឋបាលជលផលសូមជូនដំណឹងដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ឱ្យបានជ្រាបថា រដ្ឋបាលជលផលនឹងរៀបចំទទួលពាក្យសុំជួលដាយត្រីលេញ និងដាយបង្គង តាមការព្រមព្រៀង សម្រាប់ធ្វើអាជីវកម្មក្នុងរដូវនេសាទឆ្នាំ២០១៩-២០២០និងឆ្នាំ២០២០-២០២១ ចាប់ពីថ្ងៃផ្សាយដំណឹងនេះ តទៅរហូតដល់ថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ នៅរដ្ឋបាលជលផលថ្នាក់កណ្តាល ដែលមានគន្លងដាយត្រីលេញ និងដាយបង្គង ក្នុងតារាងភ្ជាប់ជាមួយនេះ។

ពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិចូលរួមជួលដាយត្រីលេញ និងដាយបង្គង លើកលែងតែមន្ត្រីរាជការ រូបវន្តបុគ្គល ឬនីតិបុគ្គលណា ដែលធ្លាប់ដេញថ្លៃបាននិងបានជួល ហើយមិនគោរពកិច្ចសន្យា ធ្លាប់បានប្រព្រឹត្តបទល្មើសនេសាទមានលក្ខណៈធ្ងន់ធ្ងរ ឬនៅជំពាក់ថ្លៃឈ្នួលដាយត្រី ដាយត្រីលេញ និងដាយបង្គង ឬប្រាក់បំណុលរដ្ឋផ្សេងៗ។

អ្នកដែលមានបំណងចង់ជួលដាយត្រីលេញ និងដាយបង្គងនេះ ត្រូវដាក់ពាក្យសុំជួលមិនឱ្យហួសពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ នៅរដ្ឋបាលជលផលថ្នាក់កណ្តាល។

សាធារណជនអាចសាកសួរព័ត៌មានបន្ថែម អំពីគំរូសំណុំលិខិតពាក្យសុំជួលដាយត្រីលេញ និងដាយបង្គង ឬព័ត៌មានផ្សេងៗទៀត នៅខណ្ឌរដ្ឋបាលជលផលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង ឬនៅរដ្ឋបាលជលផលថ្នាក់កណ្តាល រាល់ពេលម៉ោងធ្វើការ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការផ្សព្វផ្សាយជាសាធារណៈ។

ថ្ងៃពុធ ៦រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

**ចម្លងជូន៖**

- -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - «ដើម្បីជូនជ្រាបជាព័ត៌មាន»
- -អាជ្ញាធរទន្លេសាប
- -អង្គភាពប្រឆាំងអំពើពុករលួយ
- -រដ្ឋបាលខេត្តព្រៃវែង
  - «ដើម្បីជូនជ្រាបជាព័ត៌មាន»
- -មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង
- -អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ
- -ខណ្ឌរដ្ឋបាលជលផលព្រៃវែង
  - «ដើម្បីចូលរួម»
- -ឯកសារកាលប្បវត្តិ

អាសយដ្ឋានៈអាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ៥៨២ ☏/Fax: (855) 23 215 470 www.fia.gov.kh
Address #186 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh capital, Cambodia. P.O.Box 582. ☏/Fax: (855) 23 215 470 www.fia.gov.kh